Australian Government

AusAlert™

# AusAlert™ ការណែនាំអំពីសុវត្ថិភាពសម្រាប់អ្នកដែលនៅរស់រានមានជីវិត

AusAlert គឺជាប្រព័ន្ធព្រមានថ្នាក់ជាតិថ្មីរបស់ប្រទេសអូស្ត្រាលី។ វាប្រើបច្ចេកវិទ្យាចុងក្រោយបំផុតដើម្បីផ្ញើសារគ្រោះអាសន្នទៅកាន់ឧបករណ៍ចល័តនានា ក្នុងអំឡុងពេលមានគ្រោះមហន្តរាយដូចជាភ្លើងឆេះព្រៃ អាកាសធាតុអាក្រក់ធ្ងន់ធ្ងរ និងគ្រោះអាសន្នសុខភាពសាធារណៈ។



**សារ AusAlert ចែករំលែកព័ត៌មានសំខាន់ៗ ប៉ុន្តែវាអាចធ្វើឱ្យកាន់តែងាយស្វែងរកឧបករណ៍សុវត្ថិភាពដែលបានលាក់ទុក។**



## តើ AusAlert សម្រាប់ធ្វើអ្វី?

AusAlert គឺជាមធ្យោបាយដ៏លឿនមួយ និងអាចទុកចិត្តបាន ដើម្បីជួយឱ្យសហគមន៍នានាទទួលបានព័ត៌មាន និងត្រៀមបានប្រសើរជាងមុនក្នុងអំឡុងគ្រោះអាសន្នក្នុងតំបន់ និងក្នុងប្រទេស។ វាផ្តល់ឱ្យរដ្ឋាភិបាលអូស្ត្រាលី និងអង្គការសេវាកម្មសង្គ្រោះបន្ទាន់របស់រដ្ឋ និងដែនដី នូវសមត្ថភាពក្នុងការធ្វើការជូនដំណឹងក្នុងប្រទេស ឬក្នុងតំបន់។ វាគ្រាន់តែជាវិធីមួយក្នុងចំណោមវិធីជាច្រើនដែលយើងកំពុងជួយរក្សាប្រជាជនអូស្ត្រាលី ឱ្យកាន់តែមានសុវត្ថិភាពនៅពេលមានគ្រោះមហន្តរាយ។

## តើ AusAlert មានសំឡេងដូចអ្វីដែរ?

ប្រសិនបើអ្នកបើកទូរសព្ទ ថេប្លេត ឬនាឡិកាឆ្លាតវៃរបស់អ្នក AusAlert អាច៖

- ធ្វើឱ្យវាញ័រ
- បន្លឺសំឡេងខ្លាំងដូចស៊ីរ៉ែនប្រហែល 10 វិនាទី
- បើកអេក្រង់ដោយស្វ័យប្រវត្តិ។

**វាអាចកើតឡើង ទោះបីជាកម្រិតសំឡេងត្រូវបានបិទ ឬឧបករណ៍របស់អ្នកបើកដំណើរការដោយស្ងាត់ ឬកុំរំខានក៏ដោយ។**

## របៀបរក្សាសុវត្ថិភាពជាមួយ AusAlert

AusAlerts ត្រូវបានរចនាឡើងដើម្បីឱ្យពលរដ្ឋមានការយកចិត្តទុកដាក់យ៉ាងឆាប់រហ័សក្នុងអំឡុងពេលគ្រោះអាសន្ន ដើម្បីជួយរក្សាសុវត្ថិភាពពួកគេ។ **AusAlerts មួយចំនួនមិនអាចបិទបានទេ។** សម្រាប់អ្នកដែលប្រើឧបករណ៍សុវត្ថិភាព ការទទួលបាន AusAlert អាចបង្កឱ្យមានការព្រួយបារម្ភ ពីព្រោះវាអាចធ្វើឱ្យឧបករណ៍ទាំងនោះងាយស្រួលក្នុងការរកឃើញ ជាពិសេសប្រសិនបើក្នុងគោលបំណងចង់លាក់ទុកឧបករណ៍ទាំងនោះ។

### អ្វីដែលអ្នកគួរធ្វើ

ប្រសិនបើអ្នកគិតថាចុះប្រហែលជាមិនមានសុវត្ថិភាពសម្រាប់អ្នក ឬនរណាម្នាក់ដែលអ្នកយកចិត្តទុកដាក់ក្នុងការទទួលបាន AusAlert៖

- បន្តការបិទឧបករណ៍សុវត្ថិភាពរបស់អ្នក ឬ
- ក្នុង aeroplane mode (មុខងារការជិះយន្តហោះ) (ប្រសិនបើអ្នកមានវា) លើកលែងតែ
- ប្រសិនបើអ្នកត្រូវការប្រើឧបករណ៍ទាំងនោះ។

**សូមចងចាំ – អ្នកនៅតែអាចប្រើ wi-fi បាន ប្រសិនបើឧបករណ៍របស់អ្នកបើក aeroplane mode (មុខងារការជិះយន្តហោះ)។ ប្រសិនបើវាគ្មានមុខងារ aeroplane mode (មុខងារការជិះយន្តហោះ) ទេ សូមបិទវា។**



## តើខ្ញុំបិទឧបករណ៍របស់ខ្ញុំដោយរបៀបណា?

### Apple (ឧបករណ៍ដំណើរការដោយប្រព័ន្ធ iOS ដូចជា iPhone និង Apple Watches)

**ប្រសិនបើឧបករណ៍របស់អ្នកប្រើ Face ID៖**

- ចុច ហើយទប់ប៊ូតុងនៅខាងស្តាំដៃ និងប៊ូតុងកម្រិតសំឡេងក្នុងពេលតែមួយ រហូតទាល់តែ 'sliders' (ប៊ូតុងរំកិល) លេចឡើង
- អូស slider (ប៊ូតុងរំកិល) 'slide to power off' (រំកិលដើម្បីបិទភ្លើង) ពីឆ្វេងទៅស្តាំ។

**ប្រសិនបើឧបករណ៍របស់អ្នកមានប៊ូតុង Home៖**

- ចុច ហើយទប់ប៊ូតុងនៅខាងស្តាំដៃ រហូតទាល់តែ 'sliders' (ប៊ូតុងរំកិល) លេចឡើង
- អូស slider (ប៊ូតុងរំកិល) 'slide to power off' (រំកិលដើម្បីបិទភ្លើង) ពីឆ្វេងទៅស្តាំ។

ដើម្បីបើកឧបករណ៍ទាំងនេះឡើងវិញ ចុច ហើយទប់ប៊ូតុងខាងស្តាំដៃរហូតដល់ និមិត្តសញ្ញា Apple លេចឡើង។

សូមកត់ចំណាំ៖ Apple iPads **មិន**អាចទទួល AusAlerts បានទេ។

### ប្រព័ន្ធប្រតិបត្តិការ Android (ឧបករណ៍នានាដូចជាទូរសព្ទ និងថេប្លេត ហើយនិងនាឡិកាឆ្លាតវៃមួយចំនួន)

សម្រាប់ឧបករណ៍ Android៖

- ចុច ហើយទប់ប៊ូតុងបិទ/បើកភ្លើង នៅផ្នែកខាងឆ្វេង ឬក៏ខាងស្តាំនៃឧបករណ៍របស់អ្នក រហូតទាល់តែម៉ឺនុយ បិទ/បើកលេចឡើង
- ចុចប៊ូតុង 'Power Off' (បិទភ្លើង)។

ដើម្បីបើកឧបករណ៍របស់អ្នកឡើងវិញ ចុច ហើយទប់ប៊ូតុងបិទ/បើកភ្លើងឱ្យជាប់ រហូតទាល់តែរូបសញ្ញាក្រុមហ៊ុនផលិតឧបករណ៍របស់អ្នកលេចឡើង។

**សូមចងចាំផងដែរថា ត្រូវបិទឧបករណ៍សុវត្ថិភាពណាមួយដែលប្រើដោយកុមារនៅក្រោមការថែទាំរបស់អ្នក។**



## តើខ្ញុំប្តូរឧបករណ៍របស់ខ្ញុំទៅ aeroplane mode (មុខងារការជិះយន្តហោះ) ដោយរបៀបណា?

### Apple (ឧបករណ៍ដំណើរការដោយប្រព័ន្ធ iOS ដូចជា iPhone និង Apple Watches)

ដើម្បីបើក aeroplane mode (មុខងារការជិះយន្តហោះ)៖

- ចូលទៅកាន់ Settings (ការកំណត់)
- បើកប៊ូតុង 'Aeroplane Mode' (មុខងារការជិះយន្តហោះ)
- រូបតំណាងយន្តហោះគួរតែលេចឡើងនៅផ្នែកខាងលើនៃអេក្រង់។

ដើម្បីបិទ aeroplane mode (មុខងារការជិះយន្តហោះ) វិញ៖

- ចូលទៅកាន់ Settings (ការកំណត់)
- បិទប៊ូតុង 'Aeroplane Mode' (មុខងារការជិះយន្តហោះ)
- រូបតំណាងយន្តហោះនៅផ្នែកខាងលើនៃអេក្រង់គួរតែលែងមើលឃើញ។

សូមកត់ចំណាំ៖ Apple iPads **មិន**អាចទទួល AusAlerts បានទេ។

### ប្រព័ន្ធប្រតិបត្តិការ Android (ឧបករណ៍នានាដូចជាទូរសព្ទ និងថេប្លេត ហើយនិងនាឡិកាឆ្លាតវៃមួយចំនួន)

ដើម្បីបើក aeroplane mode (មុខងារការជិះយន្តហោះ)៖

- ចូលទៅកាន់ Settings (ការកំណត់)
- ចុចលើ 'Network & internet' (បណ្តាញ និងអ៊ីនធឺណិត)
- បើកប៊ូតុង 'Aeroplane Mode' (មុខងារការជិះយន្តហោះ)
  - រូបតំណាងយន្តហោះគួរតែលេចឡើងនៅផ្នែកខាងលើនៃអេក្រង់។

ដើម្បីបិទ aeroplane mode (មុខងារការជិះយន្តហោះ) វិញ៖

- ចូលទៅកាន់ Settings (ការកំណត់)
- ចុចលើ 'Network & internet' (បណ្តាញ និងអ៊ីនធឺណិត)
- បិទប៊ូតុង 'Aeroplane Mode' (មុខងារការជិះយន្តហោះ)
- រូបតំណាងយន្តហោះនៅផ្នែកខាងលើនៃអេក្រង់គួរតែលែងមើលឃើញ។

## តើ AusAlert មើលទៅមានលក្ខណៈដូចអ្វីដែរ?

អាស្រ័យលើប្រភេទឧបករណ៍ និងប្រព័ន្ធប្រតិបត្តិការរបស់អ្នក សារ AusAlert នឹងមើលទៅមានលក្ខណៈដូចនេះ៖




សារ AusAlert ដែលបង្ហាញនៅលើអេក្រង់ គឺជាឧទាហរណ៍តែប៉ុណ្ណោះ ហើយមិនមែនជា AusAlerts ពិតប្រាកដនោះទេ។

## អ្នកអាចទុកចិត្តលើ AusAlert បាន

AusAlert ត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលអូស្ត្រាលី ហើយមានសុវត្ថិភាព និងគ្មានគ្រោះថ្នាក់។ មានតែអង្គការសេវាកម្មសង្គ្រោះបន្ទាន់ដែលមានការអនុញ្ញាត និងរដ្ឋាភិបាលអូស្ត្រាលីប៉ុណ្ណោះ ដែលអាចផ្ញើ AusAlerts បាន។

AusAlert **នឹងមិន៖**

- តម្រូវឱ្យអ្នកចុះឈ្មោះដើម្បីបើកចូលទេ
- សួរព័ត៌មានផ្ទាល់ខ្លួន ឬព័ត៌មានហិរញ្ញវត្ថុទេ
- ដឹង ឬរក្សាទុកព័ត៌មានផ្ទាល់ខ្លួន ឬលេខទូរសព្ទរបស់អ្នកទេ
- តាមដានទីតាំងរបស់អ្នក ឬចែករំលែកប្រវត្តិទីតាំងរបស់អ្នក ទោះបីជាឧបករណ៍របស់អ្នកត្រូវបានភ្ជាប់ទៅលេខសម្គាល់ដែលបានចែករំលែកក៏ដោយ។

## ចុះប្រសិនបើខ្ញុំទទួលបាន AusAlert នៅលើឧបករណ៍សុវត្ថិភាពរបស់ខ្ញុំ?

ប្រសិនបើឧបករណ៍សុវត្ថិភាពរបស់អ្នកបានបើកដំណើរការ និងទទួលបាន AusAlert វានឹងបន្លឺ**សំឡេងខ្លាំងដូចស៊ីរ៉ែនប្រហែល 10 វិនាទី** ហើយបន្ទាប់មកក៏ឈប់។ វាគួរតែកើតឡើងតែម្តងប៉ុណ្ណោះ ថ្វីបើអ្នកអាចទទួលបានការជូនដំណឹងមួយផ្សេងទៀតក៏ដោយ ប្រសិនបើព័ត៌មានថ្មីអំពីគ្រោះអាសន្នត្រូវបានចែករំលែក។

ព្យាយាមរក្សាភាពស្ងប់ស្ងាត់។ **ប្រសិនបើអ្នកមិនមានសុវត្ថិភាពទេ សូមទូរសព្ទទៅលេខ 000 ភ្លាម** ហើយធ្វើតាមផែនការសុវត្ថិភាពរបស់អ្នក។

ប្រសិនបើវាមានសុវត្ថិភាពក្នុងការធ្វើដូច្នោះ សូមអានសារ AusAlert ហើយធ្វើតាមការណែនាំដើម្បីរក្សាខ្លួនអ្នក និងអ្នកដទៃឱ្យមានសុវត្ថិភាព។

## សូមតាមដានព័ត៌មាន

AusAlert គឺគ្រាន់តែជាវិធីមួយ ដើម្បីរក្សាសុវត្ថិភាពក្នុងពេលមានគ្រោះមហន្តរាយ។ អ្នកក៏អាចបើកទូរទស្សន៍ ឬវិទ្យុក្នុងតំបន់ ឬវិទ្យុជាតិ ពិនិត្យមើលកម្មវិធី (apps) សេវាកម្មសង្គ្រោះបន្ទាន់នានា ស្វែងរកតាមអនឡាញដើម្បីរកព័ត៌មានបន្ថែម ឬទាក់ទងគ្រួសារ មិត្តភក្តិ ឬអ្នកជិតខាង។

### ជំនួយ និងដំបូន្មាន

**ប្រសិនបើអ្នកព្រួយបារម្ភអំពីសុវត្ថិភាពបន្ទាន់របស់អ្នក សូមទូរសព្ទទៅលេខ 000។**

សម្រាប់ដំបូន្មាន ឬជំនួយផ្សេងៗ៖

- អំពីសុវត្ថិភាពរបស់អ្នក សូមទូរសព្ទទៅ 1800RESPECT តាមលេខ 1800 737 732
- នៅក្នុងតំបន់មូលដ្ឋានរបស់អ្នក សូមចូលទៅកាន់គេហទំព័រ ANROWS តាម **anrows.org.au/support-directory**
- ប្រសិនបើអ្នកជាជនជាតិដើម Aboriginal ឬអ្នកកោះ Torres Strait សូមទូរសព្ទទៅ 13YARN តាមលេខ 13 92 76។

DFV-Live

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ **ausalert.gov.au**